ការិយាល័យកណ្តាល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការទទួលបានការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា សម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណបៃតង របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) ជាធនាគារពាណិជ្ជទីមួយ ដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា ធនាគារ អេស៊ីលីដា បានទទួលការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា ក្នុងការបោះផ្សាយលក់សញ្ញាបណ្ណបៃតង សម្រាប់វិនិយោគិនគុណវុឌ្ឍិ។

ធនាគារ អេស៊ីលីដា កំពុងរៀបចំបំពេញតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) និងផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)។

ការបោះផ្សាយលក់សញ្ញាបណ្ណបៃតងនេះ នឹងរួមចំណែកអនុវត្តតាមគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយការបំភាយឧស្ម័នកាបូនិច និងផលប៉ះពាល់បរិស្ថាន ព្រមទាំងការលើកកម្ពស់វិស័យមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១៤រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP